*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីបិទ «សន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០២៤ និង លើកទិសដៅការងារ ឆ្នាំ ២០២៥ របស់ក្រសួងផែនការ»

រាជធានីភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ១ កើត, ខែផល្គុន, ឆ្នាំ រោង, ឆស័ក ព.ស. ២៥៦៨
ត្រូវនឹងថ្ងៃទី ២៧ ខែ កុម្ភៈ គ.ស. ២០២៥, ទីស្តីការក្រសួងផែនការ

*****+*****

- ឯកឧត្តមទេសរដ្ឋមន្ត្រី និង ឯកឧត្តមរដ្ឋមន្ត្រី;
- ឯកឧត្តម ចិន ត្រាឈៃ រដ្ឋមន្ត្រីក្រសួងផែនការ;
- ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំក្រសួងផែនការ និង តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គសន្និបាតជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានកិត្តិយសដ៏ឧត្តុង្គឧត្តម និង សេចក្តីសោមនស្សក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុត ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុងពិធីបិទ «**សន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០២៤ និង លើកទិសដៅការងារ ឆ្នាំ ២០២៥ របស់ក្រសួងផែនការ**» ។ ខ្ញុំសូមពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខ និង ក្តីនឹករលឹកដ៏ជ្រាលជ្រៅបំផុត ពីសំណាក់

**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ជូនចំពោះដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងផែនការ ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម ប៊ិន ត្រាឈៃ រដ្ឋមន្ត្រីក្រសួងផែនការ** និង ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី និង សមាជិក-សមាជិកានៃអង្គសន្និបាត ដែលបានសម្តែងនូវការស្វាគមន៍យ៉ាងពាក់ទាក់ ដល់រូបខ្ញុំ និង សហការី ក្នុងពិធីបិទសន្និបាតនេះ ។ ជាមួយគ្នានេះ, តាងនាម **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសម្តែងនូវការកោតសរសើរ, ការអបអរសាទរដោយស្មោះ និង ការវាយតម្លៃខ្ពស់ ចំពោះ **ឯកឧត្តម រដ្ឋមន្ត្រី ប៊ិន ត្រាឈៃ**, ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងផែនការ ដែលបានយកចិត្តទុកដាក់ ក្នុងការបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន, ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងវិស័យផែនការ, ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហេតុសម្រេចបាននូវលទ្ធផលការងារដ៏សំខាន់ជាច្រើន ក្នុងឆ្នាំ ២០២៤ កន្លងទៅ, និង សូមសម្តែងនូវការគាំទ្រ, ជារួម, ចំពោះទិសដៅការងារទាំងឡាយ ដែលអង្គសន្និបាតសម្រេចដាក់ចេញ សម្រាប់អនុវត្ត ក្នុងឆ្នាំ ២០២៥ នេះ សំដៅបន្តជំរុញលើកកម្ពស់អភិបាលកិច្ច និង ការអភិវឌ្ឍក្រសួងផែនការ ក៏ដូចជា អង្គភាពក្រោមឱវាទក្រសួង ព្រមទាំង ពង្រឹងនូវប្រសិទ្ធភាពការងារបន្ថែមទៀត ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ក្នុងរយៈពេលជិត ៣ ទសវត្សរ៍ ចុងក្រោយនេះ, ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ពេញផ្ទៃប្រទេស តាមរយៈ **នយោបាយ ឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា**, កម្ពុជាបន្តសម្រេចបាននូវសមិទ្ធផលដ៏ធំធេងជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលធ្វើឲ្យប្រទេស និង ជាតិយើង ទទួលបាននូវការផ្លាស់ប្តូរមុខមាត់គួរជាទីមោទនៈ ។ លើសពីនេះ, កម្ពុជាក៏ធានាបាននូវអធិបតេយ្យជាតិ, សន្តិសុខ, សុវត្ថិភាព, សណ្តាប់ធ្នាប់សង្គម និង ស្ថិរភាពនយោបាយ, ព្រមទាំងរក្សាបានយ៉ាងល្អ នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។

លើមូលដ្ឋាននេះ, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, និង ឈ្លាសវៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា,** រាជរដ្ឋាភិបាល

កម្ពុជា សម្រាប់ នីតិកាលទី ៧ នៃរដ្ឋសភា បាន និង កំពុង បន្តខិតខំចាប់យកនូវកាលានុវត្តភាពទាំងឡាយ, ដែលផុសឡើង ក្នុងបរិការណ៍នៃការផ្លាស់ប្តូរយ៉ាងរហ័ស នៃស្ថានភាពសង្គម-សេដ្ឋកិច្ច តំបន់ និង សកលលោក ។ ក្នុងគោលដៅនេះ, រាជរដ្ឋាភិបាល សម្រាប់ នីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព** និង **ចីរភាព** ដោយកំណត់យកនូវ **អាទិភាពគន្លឹះ ចំនួន ៥** គឺ៖ **មនុស្ស, ផ្លូវ, ទឹក, ភ្លើង និង បច្ចេកវិទ្យា**, ជាពិសេស **បច្ចេកវិទ្យាឌីជីថល** ដើម្បីលើក-កម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិ និង ជំរុញបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ ក្នុងការសម្រេចបាន នូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

ជាមួយនឹងកិច្ចប្រឹងប្រែងយ៉ាងសកម្ម និង ប្រកបដោយភាពបុរេសកម្មទាំងអស់នេះ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃថា អាចសម្រេចបានកំណើន ក្នុងរង្វង់ប្រមាណ ៦% នៅឆ្នាំ ២០២៤ និង ត្រូវបានព្យាករថា នឹងបន្តកើនឡើង ក្នុងរង្វង់ប្រមាណ ៦,៣% នៅឆ្នាំ ២០២៥ នេះ ។ ខ្ញុំសូមគូសបញ្ជាក់ថា, កម្ពុជាអាចសម្រេចបានកំណើនសេដ្ឋកិច្ចដ៏ល្អបែបនេះ គឺដោយសាររាជរដ្ឋាភិបាល បានដាក់ចេញ និង ជំរុញអនុវត្តយ៉ាងសកម្ម និង ទាន់ពេល នូវគោលនយោបាយត្រឹមត្រូវ, មុតស្រួច និង ចំទិសដៅ នៅតាមវិស័យសំខាន់ៗជាអាទិភាព, មានជាអាទិ៍៖ ការពង្រឹងអភិបាលកិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិន-ភាព; ការកសាងមូលធនមនុស្ស; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ; ការ-ជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច; ការស្តារនូវវិស័យជាចន្ទល់នៃកំណើនដែលមានស្រាប់, ក៏ដូចជា ការលើកកម្ពស់វិស័យសក្តានុពលថ្មីមួយចំនួនទៀត, រួមទាំងការ-វិនិយោគលើសហគ្រាស ធុនមីក្រូ, តូច, និង មធ្យម, និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ផងដែរ ។

ស្ថិតក្រោមដំបូលនៃសុខសន្តិភាពដ៏ពេញលេញ, កម្ពុជាបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ និង បន្តធ្វើបរិវត្តកម្មរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចរបស់ខ្លួន បានយ៉ាងរហ័ស, ពោលគឺ កម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសដែលមានកំណើន

សេដ្ឋកិច្ចខ្ពស់, ក្នុងអត្រាកំណើន ជាមធ្យមជាង **៧ ភាគរយ ក្នុងមួយឆ្នាំ** ក្នុងរយៈពេលជាងពីរទសវត្សរ៍ នៃដំណាក់កាលមុនវិបត្តិនៃជំងឺកូវីដ-១៩, ហើយសេដ្ឋកិច្ចកម្ពុជា ក៏បានស្ទុះងើបឡើងវិញយ៉ាងរហ័ស និង បន្តឈរលើមាគ៌ានៃកំណើនដ៏រឹងមាំ បន្ទាប់ពីវិបត្តិជាសកលនេះ ។ ត្រង់ចំណុចនេះ, ខ្ញុំសូមកត់សម្គាល់ថា តួលេខនេះ គឺផ្អែកលើទិន្នន័យគណនីជាតិ ឆ្នាំគោលថ្មី ២០១៤ ដែលការរៀបចំផ្លាស់ប្តូរឆ្នាំគោលថ្មីនេះ គឺជាសមិទ្ធផលដ៏ធំមួយផងដែរ នៃកិច្ចប្រឹង-ប្រែងរបស់ក្រសួងផែនការ ។

ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចនេះ ក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកលូតលាស់នៃមូល-ដ្ឋានគ្រឹះនៃសង្គម-សេដ្ឋកិច្ច លើគ្រប់វិស័យ, និង ការអភិវឌ្ឍសង្គម-ប្រជាសាស្ត្រ (socio-demographic development), ជាពិសេស ការកាត់បន្ថយភាពក្រីក្រ និង ការរីកចម្រើននៃសន្ទស្សន៍អភិវឌ្ឍមនុស្ស (HDI), ទាំងកម្រិតជីវភាព, ការអប់រំ និង សុខុមាលភាព របស់ប្រជាជន ។ ការណ៍នេះ បានរុញច្រានឲ្យកម្ពុជា ចេញផុតពីឋានៈជាប្រទេសមានចំណូលទាប និង បានប្រែក្លាយទៅជា **«ប្រទេសមានចំណូលមធ្យមកម្រិតទាប»** ចាប់ពីឆ្នាំ ២០១៥ មកម្ល៉េះ, ហើយបច្ចុប្បន្ន កម្ពុជាក៏កំពុងត្រៀមខ្លួនចាកចេញពី **«ចំណាត់ថ្នាក់នៃក្រុមប្រទេសអភិវឌ្ឍតិចតួច»** នៅឆ្នាំ ២០២៩ ខាងមុខផងដែរ ស្របតាមសម្ទុះនៃការអភិវឌ្ឍរបស់ខ្លួន និង អនុលោមតាមការអនុម័តរបស់អង្គការសហប្រជាជាតិ កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២៤ កន្លងទៅ ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ការចាកចេញពី **ចំណាត់ថ្នាក់នៃក្រុមប្រទេសអភិវឌ្ឍតិចតួច** របស់កម្ពុជា គឺជាសមិទ្ធ-ផល គួរជាទីមោទនៈ ដែលកើតចេញពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល, ទាំងក្នុងនីតិកាលកន្លងទៅ និង ក្នុង នីតិកាលទី ៧ នៃរដ្ឋសភា ។ ប៉ុន្តែ, ទន្ទឹមនេះ, ការណ៍នេះក៏នឹងអាចនាំមកនូវបច្ច័យមួយចំនួន ដែលយើងទាំងអស់គ្នា ត្រូវរួមគ្នាគិតគូរ និង យកចិត្តទុកដាក់ផងដែរ ក្នុងនោះរួមមាន៖ (១). ការរិចរិលនៃប្រព័ន្ធអនុគ្រោះ និង ទីផ្សារពាណិជ្ជកម្ម (Preferential trade and market access); (២). ការថមថយនូវជំនួយអភិវឌ្ឍន៍ផ្លូវការពីដៃគូ, ទាំងក្នុងទម្រង់ជាជំនួយឥតសំណង និង ជាហិរញ្ញប្បទានដែលមានកម្រិតសម្បទានខ្ពស់; (៣). ភាពងាយរងគ្រោះទៅនឹងហានិភ័យពីកត្តាខាងក្រៅ (External shock); (៤). ភាពមាន

កម្រិតនៃលំហថវិកា, ក្នុងករណីមានភាពចាំបាច់ នៃតម្រូវការចំណាយអន្តរាគមន៍ ក្នុងទ្រង់-ទ្រាយធំ ដោយប្រើប្រាស់ថវិការដ្ឋ; និង (៥). ភាពមានកម្រិតនៃសមត្ថភាពស្ថាប័ន, ទាំងក្នុងវិស័យសាធារណៈ និង វិស័យឯកជន, ក្នុងការឆ្លើយតបទៅនឹងតម្រូវការ និង និន្នាការថ្មី ។

លើសពីនេះ, កម្ពុជា ក៏ត្រូវបានបន្តហ៊ុមព័ទ្ធដោយកត្តាហានិភ័យចម្បងៗខាងក្រៅ ដែលពុំចំណុះនឹងការគ្រប់គ្រងរបស់ខ្លួនឡើយ, ក្នុងនោះ រួមមានជាអាទិ៍៖ ការបន្តប្រឈមមុខខាងភូមិសាស្ត្រនយោបាយ កាន់តែស្រួចស្រាល់; ការបែកខ្ញែកនៃសេដ្ឋកិច្ចសកល ដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការ និង ពាណិជ្ជកម្មអន្តរជាតិ; ការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យាព័ត៌មាន និង បញ្ញាសប្បនិម្មិតកាន់តែខ្លាំងក្លា; ការងើបមកវិញនៃនិន្នាការឯកតោភាគីនិយម; ភាពមិនច្បាស់លាស់នៃទស្សនវិស័យនៃកំណើនសេដ្ឋកិច្ច នៃបណ្ដាប្រទេស និង តំបន់ ជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា; ព្រមទាំង ផលវិបាកពីការប្រែប្រួលអាកាសធាតុ និង គ្រោះធម្មជាតិ ។ល។

ការណ៍នេះ តម្រូវឲ្យកម្ពុជា រៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ និង ផែនការ សម្រាប់ការអភិវឌ្ឍ ឲ្យបានច្បាស់លាស់, ត្រឹមត្រូវ និង គ្រប់ជ្រុងជ្រោយ ។ ក្នុងន័យនេះ, ស្ថិតិ នឹងដើរតួនាទីកាន់តែសំខាន់ ក្នុងការជួយឲ្យអ្នករៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ និង ផែនការ ព្រមទាំងភាគីពាក់ព័ន្ធ អាចមើលឃើញស៊ីជម្រៅ នូវរចនាសម្ព័ន្ធ, ដវភាព និង សមិទ្ធកម្មនៃសកម្មភាពសេដ្ឋកិច្ចនីមួយៗ តាមរយៈការវិភាគត្រឹមត្រូវ និង ល្អិតល្អន់ ដោយប្រែក្លាយទិន្នន័យ ទៅជាព័ត៌មាន, ចំណេះដឹង និង ផែនការសកម្មភាព ដើម្បីអាចអនុវត្តបានជាក់ស្ដែង និង ចំគោលដៅ ។ ដូច្នេះ, ការធានាឲ្យបាននូវ «**ទិន្នន័យល្អ, ស្ថិតិល្អ និង ផែនការល្អ**» គឺជាកត្តាមិនអាចខ្វះបាន ក្នុងដំណើរឆ្ពោះទៅសម្រេចនូវ «**ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**» ។ ឈរលើស្មារតីនេះហើយ ទើបរាជរដ្ឋាភិបាល បានសម្រេចប្រែក្លាយ «**វិទ្យាស្ថានជាតិស្ថិតិ**» ទៅជា **គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ** ដើម្បីពង្រឹងប្រសិទ្ធភាពនៃការ-ប្រមូល, ការកែច្នៃ, ការចងក្រង, ការវិភាគ, ការបោះពុម្ព និង ការផ្សព្វផ្សាយ ទិន្នន័យស្ថិតិគ្រឹះ និង ស្ថិតិផ្លូវការ ដើម្បីអនុញ្ញាតឲ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ និង រដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រើប្រាស់ជាធាតុចូលដ៏មានសារៈសំខាន់ សម្រាប់ជាមូលដ្ឋានដ៏រឹងមាំនៃការវិភាគ និង ការរៀបចំគោលនយោបាយនានា ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ខ្ញុំបានស្តាប់យ៉ាងយកចិត្តទុកដាក់ នូវការរាយការណ៍ ដ៏ក្បោះក្បាយ របស់ **ឯកឧត្តមរដ្ឋមន្ត្រី ឃឹន ទ្រាឡៃ** អំពីសមិទ្ធផល, បញ្ហាប្រឈមដែលក្រសួងផែនការបានជួបប្រទះ ក្នុងឆ្នាំ ២០២៤ និង ទិសដៅការងារបន្ត ។ ជារួម, ក្រសួងផែនការ បាន និង កំពុង ចូលរួមចំណែកយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកម្ពុជា, ជាពិសេស បានដើរតួនាទីជាសេនាធិការដ៏សំខាន់ លើកិច្ចការជាអាទិភាពសំខាន់ៗ រួមមាន៖ **ទី១**-ការរៀបចំ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **កម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល** ដែលជាឯកសារគន្លឹះសម្រាប់ជំរុញការអនុវត្តគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាល ស្របតាម «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» ក៏ដូចជា ការរៀបចំផែនការ និង យុទ្ធសាស្ត្រជាតិនានាផ្សេងទៀត; **ទី២**-ការបន្តអភិវឌ្ឍសង្គម-ប្រជាសាស្ត្រ ក្រោមផ្ទៃនៃការតាមដាន និង ការវាយតម្លៃការអនុវត្ត **គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០១៦-២០៣០**, ការរៀបចំ **របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត**, ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និង ជនងាយរងហានិភ័យ, និង ការលើកកម្ពស់អាហារូបត្ថម្ភ; **ទី៣**-ការបន្តពង្រឹង និង ការធ្វើវិសិដ្ឋកម្មប្រព័ន្ធស្ថិតិជាតិ សំដៅលើកកម្ពស់គុណភាពស្ថិតិផែនការ, ជាពិសេស ការប្រែក្លាយវិទ្យាស្ថានជាតិស្ថិតិ ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល សំដៅឆ្លើយតបទៅនឹងនិន្នាការនៃបរិវត្តកម្មសង្គម-សេដ្ឋកិច្ចឌីជីថល; **ទី៤**-ការបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍សំខាន់ៗ ក្រោមក្របខណ្ឌនៃការអនុវត្តកម្មវិធីសកម្មភាពរបស់ **សន្និសីទអន្តរជាតិស្តីពីប្រជាជន និង ការអភិវឌ្ឍ** (ICPD); និង **ទី៥**-ការដឹកនាំ **គណៈកម្មាធិការជាតិ សម្រាប់ការត្រៀមចាកចេញរបស់កម្ពុជា ពីចំណាត់ថ្នាក់នៃក្រុមប្រទេសអភិវឌ្ឍតិចតួច** ដើម្បីសម្របសម្រួល លើការរៀបចំយុទ្ធសាស្ត្រអន្តរកាល សម្រាប់ការចាកចេញដោយរលូន របស់កម្ពុជា នៅឆ្នាំ ២០២៩ ដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ។ ជារួម, ក្រសួងផែនការ គឺជាស្ថាប័នគោលមួយ របស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួល, ការដឹកនាំ និង ការរៀបចំគោលនយោបាយអភិវឌ្ឍជាតិសំខាន់ៗ ព្រមទាំង ក្នុងការផលិត និង ការវិភាគទិន្នន័យសម្រាប់បម្រើឲ្យការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ជាថ្មីម្តងទៀត, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី ឃឹន ទ្រាឡៃ**, **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី,** ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់

លំដាប់ថ្នាក់នៃក្រសួងផែនការ ដែលបានប្រឹងប្រែងបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ក្នុងការងារផែនការ, ស្ថិតិ និង ការអភិវឌ្ឍសង្គមប្រជាសាស្ត្រ, ជាពិសេស ក្នុងការសម្រេចបាននូវសមិទ្ធផលការងារក្នុងវិស័យសំខាន់ៗជាបន្តបន្ទាប់ ដូចត្រូវបានគូសបញ្ជាក់ខាងលើ ។ ខ្ញុំមានជំនឿថា អង្គសន្និបាត ក្នុងរយៈពេល ១ ថ្ងៃកន្លះ កន្លងទៅនេះ ក៏បានទទួលនូវធាតុចូលសំខាន់ៗ ពីបទបង្ហាញ, កិច្ចពិភាក្សា និង ការសន្ទនាផ្លាស់ប្តូរយោបល់ តាមជំនាញ និង បទពិសោធ របស់ថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់លំដាប់ថ្នាក់ ក៏ដូចជា ភាគីពាក់ព័ន្ធ សម្រាប់បន្តជំរុញវឌ្ឍនភាព និង ប្រសិទ្ធភាពការងារ ទៅអនាគត ។ ជាថ្មីម្តងទៀត, ខ្ញុំសូមគាំទ្រទាំងស្រុង ចំពោះទិសដៅការងារ ឆ្នាំ ២០២៥ របស់ក្រសួងផែនការ, ដែល **ឯកឧត្តមរដ្ឋមន្ត្រី ប៊ិន ត្រាឈៃ** បានគូសបញ្ជាក់នៅមុននេះបន្តិច ។ បន្ថែមលើនេះ, ខ្ញុំក៏សូមគូសរំលេចបន្ថែម និង ផ្ដល់អនុសាសន៍មួយចំនួន ដល់ក្រសួងផែនការ, ជាវិភាគទានក្នុងការជួយសម្រួច និង តម្រង់ទិសដៅការងារជាអាទិភាពរបស់ខ្លួន សម្រាប់ឆ្នាំ ២០២៥, ដូចខាងក្រោម៖

**ទី១.** ក្រសួងត្រូវពង្រឹងប្រសិទ្ធភាពនៃការរៀបចំ និង ការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **កម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល** ដែលជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់អនុវត្ត «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» និង ក្នុងដំណាក់កាលបន្តបន្ទាប់ទៀត ។

**ទី២.** ក្រសួងត្រូវពង្រឹងសមត្ថភាពស្ថាប័នរបស់ «**វិទ្យាស្ថានជាតិស្ថិតិ**» តាមរយៈការអភិវឌ្ឍធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពថវិកា និង ប្រសិទ្ធភាពប្រតិបត្តិការ, ទាំងក្នុងកម្រិតថ្នាក់ដឹកនាំ និង កម្រិតជំនាញបច្ចេកទេស, ព្រមទាំង ការចាប់យកបច្ចេកវិទ្យាចាំបាច់, ជាពិសេស បច្ចេកវិទ្យាឌីជីថលថ្មីៗ, សំដៅលើកកម្ពស់ និង ធ្វើវិសិដ្ឋកម្មប្រព័ន្ធស្ថិតិជាតិ ប្រកបដោយគុណភាព និង ទំនុកចិត្តខ្ពស់ ឲ្យបានទាន់ពេល សំដៅឆ្លើយតបទៅនឹងតម្រូវការនៃការរៀបចំ, ការតាមដាន និង ការវាយតម្លៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**ទី៣.** ក្រសួងត្រូវបន្តយកចិត្តទុកដាក់សិក្សាអំពីនិន្នាការប្រជាសាស្ត្រ ដោយវិភាគពីសេណារីយ៉ូនានា ដែលគិតគូរទាំងកម្មវិបាក និង កាលានុវត្តភាព នៃការប្រែប្រួលរចនាសម្ព័ន្ធអាយុរបស់ប្រជាជនកម្ពុជា សំដៅទាញយកសក្តានុពល និង ធ្វើសុភបរមូបនីយកម្ម (Optimization) នៃភាគលាភប្រជាសាស្ត្រ ។

**ទី៤.** ក្រសួងត្រូវបន្តសម្របសម្រួលដឹកនាំលើការរៀបចំយុទ្ធសាស្ត្រអន្តរកាល សម្រាប់ការ-ចាកចេញដោយរលូន របស់កម្ពុជា ពីចំណាត់ថ្នាក់នៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច នៅឆ្នាំ ២០២៩ ។

**ទី៥.** ក្រសួងត្រូវបន្តរៀបចំទិន្នន័យគណនេយ្យនៃគណនីជាតិ ឲ្យបានទាន់ពេល និង ត្រូវសម្របសម្រួលដឹកនាំការងារផ្លាស់ប្តូរឆ្នាំគោលថ្មីនៃគណនីជាតិ ពីឆ្នាំ ២០១៤ មកឆ្នាំ ២០២៤ ឲ្យសម្រេចបានជោគជ័យ តាមកាលកំណត់ ត្រឹមឆ្នាំ ២០២៦ ។

**ទី៦.** ក្រសួងក៏ត្រូវបន្តចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ឲ្យបានទាន់ពេល, ទន្ទឹមនឹងការពិនិត្យឡើងវិញ អំពីការផ្លាស់ប្តូរឆ្នាំគោល ២០០៦ ដែលត្រូវបានបន្តប្រើប្រាស់រហូតដល់បច្ចុប្បន្ន ក៏ដូចជា ត្រូវពង្រីកវិសាលភាពសន្ទស្សន៍នេះ ឲ្យទៅជាសន្ទស្សន៍ថ្នាក់ជាតិ តែម្តង ។

**ទី៧.** ក្រសួងត្រូវបន្តការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់កម្ពុជា ឲ្យកាន់តែប្រសើរ, ទន្ទឹមនឹងការសិក្សាធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រវាស់វែងភាពក្រីក្រឡើងវិញ ដោយផ្អែកលើការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្នាំ ២០២៥ ។

**ទី៨.** ក្រសួងត្រូវបន្តពង្រឹងអភិបាលកិច្ច និង សមត្ថភាពស្ថាប័ន រួមបញ្ចូលនូវ ការពង្រឹងប្រសិទ្ធ-ភាពនៃការគ្រប់គ្រងថវិកា ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែលម្អការបែងចែកភារកិច្ច, ការពង្រឹងការកសាងសមត្ថភាព និង ធនធានមនុស្ស, ក៏ដូចជា ការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និង ការកែទម្រង់នានា ឲ្យកាន់តែសកម្មឡើង ស្របតាមទិសស្លោក **«កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់»** និង ស្របតាមអភិក្រម **«ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់»** ។ និង

**ទី៩.** ក្រសួងត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ជាមួយអង្គការជាតិ និង អន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងឡាយ ដើម្បីកៀរគរការគាំទ្រ, ទាំងផ្នែកហិរញ្ញវត្ថុ និង ផ្នែកបច្ចេកទេស, សំដៅជំរុញការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង មូលធនមនុស្ស ឲ្យកាន់តែខ្ពស់ថែមទៀត ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងផែនការ នឹងបន្តខិតខំអនុវត្តតួនាទី និង ភារកិច្ចរបស់ខ្លួន ក្នុងស្មារតីកាន់តែសកម្ម និង ដោយបុរេសកម្ម សំដៅសម្រេចឲ្យបាន នូវទិសដៅការងារផែនការ ក្នុងឆ្នាំ ២០២៥ ដែលត្រូវបានដាក់ចេញ ដោយអង្គសន្និបាតលើកនេះ ។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមអបអរសាទរ, កោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី,** ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាក់ថ្នាក់ នៃក្រសួងផែនការ ដែលបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការ-បំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវ រហូតសម្រេចបាននូវលទ្ធផលការងារដ៏សំខាន់ជាច្រើន គួរឲ្យកត់សម្គាល់ ។ ទន្ទឹមនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, អង្គការជាតិ និង អន្តរជាតិទាំងអស់ ដែលបានបន្តគាំទ្រក្រសួងផែនការ ឲ្យសម្រេចបាននូវសមិទ្ធផលការងារដ៏ល្អ នាពេលកន្លងទៅ និង សូមលើកទឹកចិត្តឲ្យបន្តការគាំទ្រកាន់តែសកម្មឡើងថែមទៀត ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តមរដ្ឋមន្ត្រី ប៊ិន ត្រឈៃ**, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គសន្និបាត បានសមប្រកបដោយពុទ្ធពរ ទាំងបួនប្រការ គឺ៖ អាយុ, វណ្ណៈ, សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

តាងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសបិទ «**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២៤ និង លើកទិសដៅការងារ ឆ្នាំ ២០២៥**» របស់ក្រសួងផែនការ នាពេលនេះ ៕

*សូមអរគុណ!*